# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ០២ ៣.៣សរ-៩៧

## <u>សារាចរ</u>

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>ជម្រាបមក</u>**

**លោក ប្រធានតុលាការគ្រប់ជាន់ថ្នាក់**
**លោក អគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាគ្រប់ជាន់ថ្នាក់**

<u>សូមជ្រាប</u>

**<u>កម្មវត្ថុ:</u>** អំពីការទុកប្រាក់ប្រដាប់ក្តី និងប្រាក់ពិន័យផ្សេងៗឬប្រាក់ដទៃទៀតនៅក្នុងហិបប្រាក់តុលាការ ។

**<u>យោង:</u>** ប្រកាសលេខ ០១៤ ប្រក សហវ.រជ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៧ ស្តីពីការកំណត់ចំនួនទឹកប្រាក់ដែលអាចរក្សាទុកនៅក្នុងបេឡាតុលាការ ។

ក្រសួងយុត្តិធម៌ សូមចម្លងប្រកាសយោងខាងលើមកតុលាការគ្រប់ជាន់ថ្នាក់ដើម្បីអនុវត្តតទៅ ។

តាមប្រកាសនេះ បេឡាតុលាការកំពូល សាលាឧទ្ធរណ៍ និងតុលាការក្រុងភ្នំពេញ អាចរក្សាទុកក្នុងបេឡារបស់ខ្លួនកម្រិតត្រឹមចំនួន៥,០០០,០០០៛ (ប្រាំលានរៀល ) ។

បេឡានៃតុលាការខេត្ត-ក្រុង នានាអាចរក្សាទុកនូវប្រាក់រៀលក្នុងបេឡា របស់ខ្លួនត្រឹមចំនួន២,០០០,០០០៛ (ពីរលានរៀល) ។

បេឡាករមិនត្រូវទុកប្រាក់រៀលនៅក្នុងបេឡារបស់ខ្លួនអោយលើសពីចំនួន ដែលបានកម្រិតខាងលើនេះទេ ក្នុងករណីអនុវត្តផ្ទុយពីនេះត្រូវទទួលពិន័យនិងទណ្ឌកម្មតាមច្បាប់ជាធរមាន ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្គួន**